# អ្នកស្រលាញ់ភេទដូចគ្នាថា នៅតែរងការរើសអើងពីសង្គម

ដោយ លោក ណាត សុភាព | ថ្ងៃព្រហស្បតិ៍ ទី៨ ខែមីនា ឆ្នាំ២០១៨ ម៉ោង 3:39 PM | សិទ្ធិមនុស្ស | 0 | 1018

ក្រុមអ្នកស្រលាញ់ភេទដូចគ្នាបានឱ្យដឹងថា ពួកគេនៅតែរងការរើសអើងពីសាច់ញាតិ និងប្រជាពលរដ្ឋទូទៅ ដោយថាទោះជាពួកគេខំធ្វើជាមនុស្សល្អ និងជួយការងារសង្គមក្តី។

ក្នុងកម្មវិធីផ្សព្វផ្សាយគម្រោង សមភាពយេនឌ័ររយៈពេល៤ឆ្នាំ របស់ក្រុមអង្គការដែលធ្វើការពាក់ព័ន្ធស្ត្រី ស្តីពី **«សំឡេងយើង ដើម្បីសមភាពយេនឌ័រ»** កាលពីថ្ងៃទី៧ ខែមីនា ម្សិលមិញ អ្នកនាង ឈុន រចនា ដែលអះអាងថា តុបតែងខ្លួនធ្វើជាមនុស្សប្រុស ហើយស្រលាញ់ស្រីរយៈពេល១៦ឆ្នាំមកហើយនោះ បានរៀបរាប់ថា បច្ចុប្បន្ននេះ សាច់ញាតិរបស់គាត់មិនពេញចិត្ត និងរងការរិះគន់ពីមជ្ឈដ្ឋានទូទៅជាដើម។

អ្នកនាងនិយាយថា«នៅពេលដែលចេញមុខគឺមានការរើសអើងអំពីសាច់ញាតិបងប្អូន ក៏ដូចជាប្រយោជន៍ពីក្រុមគ្រួសារដែរ ហើយនៅកន្លែងធ្វើការ ក៏ខ្ញុំធ្លាប់ជួបបទពិសោធន៍នៅក្នុងការដែលគាត់រើសអើងទៅលើអត្តចរិតនៃការស្លៀកពាក់ ដែលយើងស្លៀកជាសំលៀកបំពាក់មនុស្សប្រុស ហើយនៅពេលនៅទីសាធារណៈជាដើមគឺអាចជាមានការរើសអើង ហៅថាជាស្រី ឬក៏ជាប្រុស ហើយពេលខ្លះសូម្បីតែទៅក្នុងបន្ទប់ទឹក យើងទៅបន្ទប់ទឹកមនុស្សស្រី ក៏ត្រូវបានគេមើលលើមើលក្រោមដូចជាប្លែក»។

ក្រុមអង្គការទាំងនោះរួមមាន អង្គការដានឈើច្អរអេដ(DCA) មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ប.ស.ម.ក) មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ(CCIM) និងគណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ (NGO CEDAW)។

ក្នុងកម្មវិធីនោះ អង្គការពាក់ព័ន្ធ បានផលិតជាខ្សែវីដេអូសួតខ្លីៗ និយាយពីគុណសម្បត្តិនិងគុណវិបត្តិ ចំពោះគូស្រករដែលស្រលាញ់ភេទដូចគ្នា និងសម្តែងសិល្បៈបង្ហាញជាសារបែបអប់រំជាដើម។

អ្នកនាង គ្រី សុភាព ដែលតុបតែងខ្លួនធ្វើដូចជាមនុស្សប្រុស បានឱ្យដឹងដែរថា គាត់ក៏រងការរើសអើងពីសាច់ញាតិ និងមជ្ឈដ្ឋានទូទៅដែរ។ ទោះជាបែបនេះក្តី អ្នកនាងបញ្ជាក់ថា គាត់មិនចាប់អារម្មណ៍នោះទេដោយថា នឹងព្យាយាមពន្យល់និងអប់រំ ដល់ពួកគេឱ្យយល់ពីសមភាពយេនឌ័រ បន្ទាប់ពីចូលរួមកម្មវិធីនេះរួច។

អ្នកនាងនិយាយថា «យើងនិងចែករំលែកទៅក្រុមយុវជនដែលប្រឈមមុខ ដូចជាខាងខ្ញុំ...ពួកខ្ញុំអាចនិយាយបានឬក៏ពន្យល់គាត់ឲ្យបាន យល់ច្បាស់អំពីបញ្ហានិន្នាការភេទ ឬក៏ជាសិទ្ធិរបស់ខ្លួនឯង ថាយើងត្រូវធ្វើខ្លួនឯងបែបម៉េចខ្លះ ដើម្បីការពារអំពើហិង្សានៃការរើសអើងពីសំណាក់គ្រួសារ ពីសង្គមជុំវិញ ពីសាលារៀន ឬក៏ពីទីកន្លែងជុំវិញខ្លួនរបស់យើង»។

ប្រធានអង្គការ CEDAW លោកស្រី ពុង ជីវកេក ផ្តល់ជាអនុសាសន៍ថា ដើម្បីកុំឲ្យមានការរើសអើងលើក្រុមអ្នកស្រឡាញ់ភេទដូចគ្នា រដ្ឋាភិបាលត្រូវបង្កើតច្បាប់ធានាឲ្យពួកគេមានសិទ្ធិរៀបការបានដូចបុរសនិងស្ត្រីដែរ និងធ្វើការអប់រំផ្សាយផ្សាយឲ្យបានទូលំទូលាយពីសមភាពយេនឌ័រនេះ។

ប៉ុន្តែលោកស្រីបញ្ជាក់ថា បើរដ្ឋាភិបាលមិនគិតគូដល់ក្រុមអ្នកស្រលាញ់ភេទដូចគ្នា អាចធ្វើឲ្យអ្នកទាំងនោះរងគ្រោះកាន់តែច្រើន និងធ្វើឲ្យសង្គមជាតិជួបការលំបាកនៅថ្ងៃអនាគត។

លោកស្រីផ្តល់ជាអនុសាសន៍ថា«បើមិនគិតគូទេ យើងអាចប្រឈមមុខ ក្នុងសង្គមយើងព្រោះអ្នកដែលស្រលាញ់ ភេទដូចគ្នាគាត់ទៅជាជនរងគ្រោះ ថ្ងៃណាមួយគាត់មិនសប្បាយចិត្ត គាត់អាចមានបញ្ហា ប៉ុន្តែខ្ញុំសង្ឃឹមថា រដ្ឋាភិបាលនិងយកចិត្តទុកដាក់លើអ្នកទាំងអស់គ្នាហ្នឹង»។

ក្នុងសេចក្តីថ្លែងការណ៍រួមរបស់ក្រុមអង្គការ (DCA) (ប.ស.ម.ក) (CCIM) និងអង្គការ (NGOCEDAW)ចុះផ្សាយកាលពីថ្ងៃទី៧ មីនា ឲ្យដឹងថា ស្ត្រីកម្ពុជានៅតែប្រឈមនឹងហានិភ័យខ្ពស់ពីអំពើហិង្សាផ្អែកលើយេនឌ័រ ដោយស្ត្រីមានដៃគូរហូតដល់២៥ភាគរយ ធ្លាប់ទទួលរងការបំពានលើរូបរាងកាយ និងផ្លូវភេទ ខណៈអ្នកស្រលាញ់ភេទដូចគ្នា និងស្ត្រីទូទៅ នៅតែប្រឈមនឹងភាពមិនស្មើគ្នា ហើយបុគ្គលដែលហ៊ានក្រោកឈរទាមទារសិទ្ធិរបស់ខ្លួន ត្រូវបានគេរើសអើងកាន់តែខ្លាំង ប្រឈមអំពើហិង្សាធ្ងន់ធ្ងរទាំងក្នុងគ្រួសារ និងមជ្ឈដ្ឋានខាងក្រៅ ខណៈដំណោះស្រាយមិនទាន់ទទួលបានពេញលេញនៅឡើយ។

សេក្តីថ្លែងការណ៍ដដែល បានជំរុញទៅរដ្ឋាភិបាល និងភាគីពាក់ព័ន្ធទាំងអស់ ជាពិសេសក្រសួងកិច្ចការនារី ធានាឲ្យមានដំណើរការកិច្ចពិគ្រោះយោបល់វិសោធនកម្មច្បាប់ហិង្សាក្នុងគ្រួសារជាបន្តទៀត ដើម្បីឲ្យស្ត្រី ក្មេងស្ត្រី និងអ្នកស្រឡាញ់ភេទដូចគ្នានៅទូទាំងប្រទេសទទួលបានកិច្ចការពារពេញលេញ ពីអំពើហិង្សាគ្រប់ប្រភេទ។

តាមរបាយការណ៍មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាឆ្នាំ២០១៦ បានឲ្យដឹងថា ក្រុមអ្នកស្រឡាញ់ភេទ ដូចគ្នា នៅកម្ពុជា មានចំនួន ១លាន៤សែននាក់៕

សេចក្តីលំអិតសូមទៅកាន់ទំព័រលីង: http://vodhotnews.com/08/03/2018/lgbt-people-still-suffer-from-general-population/